ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា
លេខ.១.០.៨.៤.កធស.

រាជធានីភ្នំពេញ ថ្ងៃទី៧...ខែ.ក្ក...ឆ្នាំ២០០០

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
ប្រគេន-ជំរាបមក
ព្រះមេគណគ្រប់ព្រះអង្គ ព្រះចៅអធិការគ្រប់វត្ត
លោក លោកស្រី នាយកមន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត ក្រុង
លោក លោកស្រី ប្រធានការិយាល័យធម្មការ និងសាសនា គ្រប់ស្រុក ខ័ណ្ឌ

កម្មវត្ថុ: អនុវត្តការហាមឃាត់ជក់បារីនៅតាមកន្លែងធ្វើការ គ្រឹះស្ថានពុទ្ធិកសិក្សា សាលប្រជុំនានា ឧបដ្ឋានសាលា ព្រះវិហារ រោងមហោស្រព ។

យោង: លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១២៧០ សជណ.អវ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ១៩៩៤ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដើម្បីជាគំរូដល់ប្រជាពលរដ្ឋយើង ក្នុងការមិនជក់បារី ក្រសួងសំណូមពរអោយបណ្តាមន្ទីរ អង្គភាព គ្រឹះស្ថានពុទ្ធិកសិក្សានានា វត្តអារាមក្រោមឱវាទក្រសួង យកចិត្តទុកដាក់រៀបចំអោយមានការផ្សព្វផ្សាយអប់រំទប់ស្កាត់ការជក់បារី នៅកន្លែងធ្វើការរួមគ្នា សាលប្រជុំ គ្រឹះស្ថានពុទ្ធិកសិក្សា និងឧបដ្ឋានសាលា។

ទន្ទឹមនឹងនេះ បើមន្ទីរ អង្គភាព គ្រឹះស្ថានពុទ្ធិកសិក្សាយល់ថា មិនទាន់អាចបំបាត់ការជក់បារីទាំងស្រុងទេ ស្នើសុំអោយមានការហាមឃាត់ការជក់បារីនៅក្នុងថ្នាក់រៀន បន្ទប់ធ្វើការ ឧបដ្ឋានសាលា ព្រះវិហារ អាសនៈតាំងសីល និងកុដិ ជៀសវាងប៉ះពាល់ដល់សុខភាពអ្នកដទៃដែលមិនជក់។ ព្រមជាមួយនេះ ក៏ស្នើមន្ទីរ អង្គភាព គ្រឹះស្ថានពុទ្ធិកសិក្សា វត្តអារាម រៀបចំបិទរូបភាព ផ្សព្វផ្សាយ អប់រំសុខភាព ស្តីពីផលប៉ះពាល់ដល់សុខភាព ដោយសារការជក់បារី ។

ក្រសួងធម្មការ និងសាសនា សង្ឃឹមថា ព្រះមេគណ ព្រះចៅអធិការ អស់លោក លោកស្រី ពិតជាខិតខំយកចិត្តទុកដាក់អនុវត្តអោយបានលទ្ធផល ល្អប្រសើរតាមសេចក្តីណែនាំនេះ ។

សូមព្រះមេគណ ព្រះចៅអធិការ អស់លោក លោកស្រីទទួលនូវការគោរពសក្ការៈ និងរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំព្រះករុណា-ខ្ញុំ ។

រដ្ឋមន្ត្រី

ជា-សាវឿន

ចំលងជូន:
-ក្រសួងព្រះសង្ឃរាជទាំងពីរគណៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង-មន្ទីរពាក់ព័ន្ធ
-អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ *"ដើម្បីជ្រាបជាពត៌មាន"*
-គ្រប់មន្ទីរ-ការិយាល័យ ធម្មការ និងសាសនា
-គ្រប់គ្រឹះស្ថានពុទ្ធិកសិក្សា វត្តអារាម *"ដើម្បីអនុវត្ត"*
-កាលប្បវត្តិ